

ក្រុមការងារបច្ចេកទេសអន្តរក្រសួងOCSE
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# មគ្គុទ្ទេសន៍ស្តីពី
# ការបង្ការនិងការឆ្លើយតបចំពោះអំពើកេង
# ប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

# អារម្ភកថា

សៀវភៅមគ្គុទ្ទេសន៍នេះ ត្រូវបានបង្កើតឡើងដោយអង្គការសកម្មភាពដើម្បីកុមារ ( **APLE** ) ដែលជាផ្នែកមួយរបស់គម្រោង “ការពង្រឹងការការពារកុមារនៅកម្ពុជាប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ" ដែលជាជំនួយរបស់អង្គការ **ECPAT** នៃប្រទេសស៊ុយអែត។

សៀវភៅនេះត្រូវបានធ្វើឡើងដើម្បីជួយឪពុកម្តាយ និងអ្នកថែទាំកុមារឲ្យសម្គាល់បាននូវការគម្រាមកំហែងលើកុមារតាមអនឡាញ ដើម្បីកាត់បន្ថយហានិភ័យសម្រាប់កុមារពេលពួកគេកំពុងអនឡាញ និងដើម្បីដឹងពីកន្លែងរាយការណ៍ ប្រសិនបើកុមារទទួលរងនូវអំពើកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គការ **ECPAT** នៃប្រទេសស៊ុយអែត សម្រាប់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការបង្កើតសៀវភៅមគ្គុទ្ទេសន៍នេះឡើង និងសូមថ្លែងអំណរគុណដល់អង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា **UNICEF Cambodia** និងទីភ្នាក់ងារផ្តល់ជំនួយរបស់សហរដ្ឋអាមេរិក **USAID** ក្នុងការឧបត្ថម្ភជាថវិកាសម្រាប់ការបោះពុម្ព និងការរចនា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ( **CNCC** ) សម្រាប់ការកែលម្អនូវព័ត៌មាន និងផ្តល់ជាមតិយោបល់។

យើងខ្ញុំសង្ឃឹមថា ព័ត៌មាននេះនឹងជួយលោកអ្នក ធានាបានថា កុមារទទួលបានជំនួយដែលពួកគេត្រូវការដើម្បីរក្សាសុវត្ថិភាពរបស់ពួកគេពីការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។

ផលិតដោយ៖

**APLE**

រក្សាសិទ្ធិដោយអង្គការសកម្មភាពដើម្បីកុមារ ( **APLE** )

**www.aplecambodia.org**

**www.internethotlinecambodia.org**



# បញ្ហាដែលអាចកើតមាន

ការជឿនលឿនផ្នែកបច្ចេកវិទ្យា និងការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធឺណិតនៅទូទាំងពិភពលោកបាន បង្កើននិន្នាការថ្មីគួរឱ្យព្រួយបារម្ភដែលអាចនាំឱ្យកុមារប្រឈមនឹងហានិភ័យ។ខណៈដែលអ្នកប្រើប្រាស់ អ៊ីនធឺណិតស្ទើរតែម្នាក់ក្នុងចំណោម៣នាក់ជាកុមារ ជនល្មើសផ្លូវភេទលើកុមារកំពុងតែប្រើប្រាស់អ៊ីនធឺណិត ដើម្បីទាក់ទងជាមួយកុមារ និងសម្របសម្រួលដើម្បីប្រព្រឹត្តអំពើកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទ ដែលអាចកើតឡើងចំពោះកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ។ វារួមបញ្ចូលទាំងការប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬ បណ្តាលឱ្យកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬ បញ្ជូននូវរូបភាព ឬសម្ភារៈដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

នៅប្រទេសកម្ពុជា ការវិភាគស្ថានភាពមួយលើប្រធានបទ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ ក្នុងប្រទេសកម្ពុជា ដែលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្ហាញថា ក្នុងចំណោម កុមារ ២២០នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ ម្នាក់ក្នុងចំណោម ៦នាក់ ធ្លាប់ប្រឈមនឹង ហានិភ័យដែលទាក់ទងទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ ដែលភាគច្រើនក្នុងទម្រង់នៃ ការលួងលោម ឬ ទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទពីមនុស្សពេញវ័យតាមអនឡាញ។ការកើនឡើង នៃការប្រើប្រាស់អ៊ីនធឺណិតក្នុងចំណោមកុមារនៅកម្ពុជា បូករួមទាំងការមានកម្រិតទាបផ្នែកចំណេះដឹង របស់ឪពុកម្តាយ និងអ្នកថែទាំកុមារអំពីហានិភ័យផ្សេងៗ ជាហេតុនាំឲ្យមានការកើនឡើងនៃចំនួនកុមារ ដែលប្រឈមនឹងហានិភ័យពីការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។

# ទម្រង់ទូទៅនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ




## ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ

ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ (Online Grooming) សំដៅទៅលើជនខិលខូចដែល ព្យាយាមទាក់ទងកុមារតាមប្រព័ន្ធអនឡាញ ដើម្បីកសាងទំនុកចិត្តក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពួកគេ។ ការលួងលោមទាំងនោះរួមមានការបង្ហាញនូវសម្ភារៈអាសអាភាស ដូចជា តាមរយៈការផ្ញើនូវ មាតិកា សារ វីដេអូ ឬ រូបភាពបែបផ្លូវភេទទៅកាន់កុមារ។ វិធីទាំងនេះអាចជួយឱ្យជនល្មើសផ្លូវភេទលើកុមារអាចបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទ ក្នុងគោលដៅបង្កើនឱកាសឱ្យកុមារបញ្ជូនសម្ភារៈផ្លូវភេទដោយខ្លួនឯងទៅអោយជនល្មើស។




## រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ

រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ (CSAM) សំដៅលើសម្ភារៈដែលបង្ហាញពីកុមារក្នុងស្ថានភាពអាក្រាត ពិពណ៌នាដោយផ្តោតលើកេរភេទរបស់កុមារ ឬសម្ភារៈដែលពណ៌នាអំពីកុមារនៅក្នុងស្ថានភាពបែបអាសអាភាស។ សម្ភារៈទាំងនោះរួមមាន រូបភាព វីដេអូ អត្ថបទ និងសារសម្លេង ដែលមានលក្ខណៈបែបអាសអាភាសជាដើម។



## ការផ្ញើសារបែបផ្លូវភេទ

ការបញ្ជូនសារបែបផ្លូវភេទ ( Sexting ) គឺជាសកម្មភាពនៃការផ្ញើ ឬទទួលរូបភាពបែបផ្លូវភេទ ដែលបង្កើតឡើងដោយខ្លួនឯងទៅអោយអ្នកដទៃផ្សេងទៀត។ ពេលខ្លះ ការផ្ញើ ឬការបញ្ជូន រូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯង ត្រូវបានធ្វើឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើង បន្ទាប់ពីទទួលរងការគំរាមកំហែង ការដាក់សម្ពាធ ការរៀបចំឡើង និង/ឬការបង្ខិតបង្ខំពី មនុស្សម្នាក់ទៀត។




## ការគំរាមបែបផ្លូវភេទលើកុមារ

ការគំរាមបែបផ្លូវភេទ ( Sextortion ) គឺជាទង្វើដែលជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់សម្ភារៈ រំលោភបំពានផ្លូវភេទដែលបានទទួលពីកុមារ ជាញឹកញាប់តាមរយៈ ការផ្ញើ ឬការបញ្ជូនរូបភាព ផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯង ដើម្បីគំរាមកុមារឱ្យបញ្ជូនសម្ភារៈផ្លូវភេទបន្ថែមទៀតដល់ ពួកគេ ដើម្បីជួបផ្ទាល់ក្នុងគោលបំណងផ្លូវភេទ ឬដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងទៀត ដូចជា លុយកាក់ ឬការគ្រប់គ្រង លើកុមារជាដើម។



## ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ

ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ ( Live Online Child Sexual Abuse ) សំដៅលើការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទពាក់ព័ន្ធកុមារ ឬការឱ្យកុមារសំដែងបែបផ្លូវភេទនៅមុខកាម៉េរា (អាចក្នុងស្ថានភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ ) ពេលខ្លះជនល្មើសផ្លូវភេទលើកុមារ អាចផ្តល់ជាប្រាក់ដល់កុមារផ្ទាល់ អ្នកសម្របសម្រួល ឬអន្តរការី ដើម្បីដោះដូរជាមួយនឹងសកម្មភាពនោះ។

# ៧ចំណុចសំខាន់ៗដែលត្រូវចងចាំ!

## ១ កុមារមិនត្រូវបានគេស្តីបន្ទោសចំពោះករណីរំលោភបំពានឡើយ បើទោះបីជាពួកគេបានចូលរួមក្នុងសកម្មភាពនោះក៏ដោយ



ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតែងតែជាកំហុសរបស់ជនល្មើស វាមិនមែនជាកំហុសរបស់កុមារនោះទេ បើទោះបីជាពេលខ្លះកុមារប្រាស្រ័យទាក់ទងជាមួយជនល្មើស ឬហាក់ដូចជាយល់ព្រមចូលរួមក្នុងសកម្មភាពផ្លូវភេទក៏ដោយ។ ទាំងនោះគឺដោយសារតែពួកគេមិនបានយល់ច្បាស់ជាមុនពីអ្វីដែលពួកគេបានធ្វើ ឬផលវិបាកដែលអាចកើតឡើងពីសកម្មភាពរបស់ពួកគេនោះទេ។

## ២ បើទោះបីជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពេលខ្លះមិនមានការជួបទាក់ទងផ្ទាល់ជាមួយជនល្មើសក៏ដោយ តែវានៅតែអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដូចការជួបផ្ទាល់ដែរ



ទម្រង់ជាច្រើននៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសតាមប្រព័ន្ធអនឡាញអាចកើតឡើងបានដោយមិនចាំបាច់ទាល់តែមានការជួបផ្ទាល់ ឬការប៉ះពាល់រាងកាយផ្ទាល់រវាងជនល្មើស និងកុមារនោះឡើយ។ ឧទាហរណ៍ដូចជាការថតរូបកុមារបែបផ្លូវភេទ ការចែកចាយរូបភាពទាំងនោះតាមប្រព័ន្ធអនឡាញ ឬការបង្ហាញឱ្យកុមារឃើញនូវរូបភាពបែបផ្លូវភេទជាដើម។

## ៣ ការផ្ដល់ជាប្រាក់កាស វត្ថុមានតម្លៃ ឬអំណោយជាថ្នូរនឹងការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទគឺជាការកេងប្រវ័ញ្ច



ជនល្មើសផ្លូវភេទលើកុមារតែងតែកេងប្រវ័ញ្ចកុមារដោយផ្ដល់ ឬសន្យាផ្ដល់ឱ្យពួកគេនូវអ្វីដែលពួកគេត្រូវការ ដើម្បីបញ្ចុះបញ្ចូលកុមារឱ្យធ្វើសកម្មភាពផ្លូវភេទ ហើយឆ្លៀតឱកាសដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនពីកុមារ។ ទង្វើនេះត្រូវបានចាត់ទុកជាអំពើខុសច្បាប់ដែលត្រូវផ្ដន្ទាទោស។

## ៤ ទាំងកុមារា និងកុមារីអាចត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ



ទាំងកុមារា និងកុមារីសុទ្ធតែអាចជួបហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទដូចគ្នាដែរ។ ការមិនបានយល់ដឹងថាកុមារាក៏អាចជាជនរងគ្រោះដែរនោះ បានធ្វើឱ្យកុមារាទទួលរងនូវភាពងាយរងគ្រោះ ព្រោះថាពួកគេនឹងមិនទទួលបានជំនួយដែលពួកគេត្រូវការបានល្អប្រសើរទេ បន្ទាប់ពីទទួលរងនូវការកេងប្រវ័ញ្ច។

## ៥ ជនល្មើសផ្លូវភេទលើកុមារភាគច្រើនជាមនុស្សដែលកុមារស្គាល់



ជារឿយៗកុមារតែងត្រូវបានគេបោកបញ្ឆោត ឬលួងលោមដោយមនុស្សដែលកុមារជឿទុកចិត្ត ហើយយល់ព្រមផ្ញើរូបភាពសម្ភារៈផ្លូវភេទដល់ជនល្មើសតាមប្រព័ន្ធអនឡាញ( យោងតាមការសិក្សាស្រាវជ្រាវជាច្រើន )។

## ៦ ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវចាប់ផ្តើមដោយការប្រាស្រ័យទាក់ទងដោយបើកចំហ ហើយ មិនគួរហាមកុមារប្រើប្រាស់ប្រព័ន្ធអនឡាញនោះទេ



ការហាមកុមារប្រើប្រាស់អ៊ីនធឺណិតគឺមិនមានប្រសិទ្ធិភាព ឬ សមហេតុផលនោះទេ។ កុមារនឹងទទួលបានការការពារល្អប្រសើរ ប្រសិនបើពួកគេបានដឹងពីវិធីក្នុងការសម្រេចចិត្តបានត្រឹមត្រូវ ក៏ដូចជាដឹងពីការប្រព្រឹត្តនូវទង្វើប្រកបដោយសុវត្ថិភាព និងឆ្លាតវៃនៅពេលប្រើប្រាស់ប្រព័ន្ធអនឡាញ។

## ៧ កុមារគ្រប់វ័យ សុទ្ធតែអាចជួបហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ




ការពិភាក្សា ឬការណែនាំកុមារពីសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញគួរតែចាប់ផ្តើមតាំងពីពេលដែលពួកគេមានអាយុតិច និងជាពិសេសតាំងពីពេលដែលពួកគេចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធអនឡាញ។



# ចូរនិយាយពីបញ្ហាកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ!

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺជាបទល្មើសធ្ងន់ធ្ងរដែលអាចជះឥទ្ធិពលខ្លាំងដល់កុមារ។ វាជារឿងដ៏សំខាន់ដើម្បីលើកទឹកចិត្តកុមារឱ្យនិយាយនូវអ្វីដែលបានកើតឡើង ប្រសិនបើពួកគេស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែង ឬកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។ ការនិយាយអំពីបញ្ហាកេងប្រវ័ញ្ចអាចនាំឱ្យកុមារមានសុវត្ថិភាព ឬនាំឱ្យកុមារ និងគ្រួសារទទួលបានជំនួយនិងការគាំទ្រនានា។

ប្រសិនបើសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សូមនិយាយជាមួយកុមារ និងសង្កេតមើលថាតើពួកគេត្រូវការជំនួយពីអ្នកដែរឬទេ។ ប្រសិនបើកុមារប្រាប់អ្នកពីការរំលោភបំពានណាមួយ អ្នកត្រូវ៖

- ស្តាប់ដោយការយកចិត្តទុកដាក់ មិនវិនិច្ឆ័យ និងត្រូវមានភាពហ្មត់ចត់ចំពោះអ្វីដែលកុមារនិយាយប្រាប់
- ប្រាកដថាការដែលកុមារនិយាយអំពីរឿងរ៉ាវដែលបានកើតឡើង និងការដែលកុមារមករកអ្នកឱ្យជួយគឺជារឿងត្រឹមត្រូវបំផុត
- ប្រាប់កុមារថាវាមិនមែនជារឿងដែលត្រូវខ្មាស់អៀនទេ ក្នុងការប្រាប់ពីរឿងរ៉ាវនៃការកេងប្រវ័ញ្ចដែលបានកើតឡើង ហើយរាល់កំហុសដែលកើតមានជាការទទួលខុសត្រូវរបស់ជនល្មើស
- ប្រាប់កុមារថាពួកគេមិនបានធ្វើអ្វីខុសឆ្គង ហើយពួកគេមិនត្រូវបានទទួលការស្តីបន្ទោសជាដាច់ខាត
- បង្ហាញពីការអាណិតអាសូរ និងផ្តល់ការគាំទ្រនានា

# កុំព្រងើយកន្តើយ សូមរាយការណ៍!

**អ្នកក៏អាចជួយបញ្ឈប់នូវការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញបានដែរ ប្រសិនបើអ្នកដឹងពីករណីទាំងនោះ។ សូមរាយការណ៍!**

## តើហេតុអ្វីបានជាអ្នកត្រូវរាយការណ៍?

- ការរាយការណ៍អាចជួយលុបចោលនូវរូបភាព សម្ភារៈរំលោភបំពានផ្លូវភេទចេញពីអ៊ីនធឺណិត និងជួយបញ្ឈប់រាល់ការកេងប្រវ័ញ្ចផ្សេងៗ។
- ការរាយការណ៍ក៏អាចជួយឱ្យកុមារទទួលបាននូវការគាំទ្រ និងជំនួយនានា
- ការរាយការណ៍ជួយនាំយកជនល្មើសមកទទួលទោសតាមច្បាប់
- ការរាយការណ៍កាន់តែច្រើននាំឱ្យជនល្មើសកាន់តែខ្លាចរអារក្នុងការប្រព្រឹត្តបទល្មើស
- ការរាយការណ៍អាចធ្វើឡើងដោយអនាមិក

## របៀបរាយការណ៍៖



**ទី១៖** ចូលទៅកាន់គេហទំព័រ **www.internethotlinecambodia.org**

**ទី២៖** ចុចប៊ូតុង **Report Abuse** ឬ **រាយការណ៍ការរំលោភបំពាន**

**ទី៣៖** ជ្រើសរើសយកប្រភេទករណីនៃការរំលោភបំពាន ឬកេងប្រវ័ញ្ច ណាមួយដែលអ្នកចង់រាយការណ៍ រួចបំពេញទម្រង់ឱ្យបានត្រឹមត្រូវ

**ទី៤៖** ចុចប៊ូតុងបញ្ជូន

✓ អ្នកនឹងទទួលបានសារបញ្ជាក់ពីការបញ្ជូនការរាយការណ៍របស់អ្នកដោយជោគជ័យ។

## ដំណើរការវិភាគ និងចាត់ការលើការរាយការណ៍

អង្គការសកម្មភាពដើម្បីកុមារទទួលបានការរាយការណ៍

ភាពស្របច្បាប់នៃព័ត៌មានត្រូវបានវិភាគ និងវាយតម្លៃ

ភ្នាក់ងារអនុវត្តច្បាប់ និង/ ឬ អ្នកផ្តល់សេវាកម្មអ៊ីនធឺណិតត្រូវបានផ្តល់ដំណឹង

សម្ភារៈខុសច្បាប់ត្រូវបានដកចេញពីគេហទំព័រ

អ្នកក៏អាចរាយការណ៍ទៅនគរបាលជាតិ តាមរយៈលេខទូរស័ព្ទ **1288** ឬទៅអង្គការសកម្មភាពដើម្បីកុមារ តាមរយៈលេខទូរស័ព្ទ ២៤ម៉ោង **092 311 511**

**ការរាយការណ៍របស់អ្នកអាចជួយការពារកុមារពីការរំលោភបំពាន ដែលអាចកើតឡើងក្រោយៗទៀត!**

# សារសុវត្ថិភាព

## រៀនហើយរៀនទៀត

ប្រព័ន្ធអ៊ីនធឺណិតកំពុងតែផ្លាស់ប្តូរ និងជឿនលឿនឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ហើយវាក៏មិនមានភាពងាយស្រួលដែរក្នុងការតាមដាននូវកម្មវិធីថ្មីៗ ក៏ដូចជាផលប៉ះពាល់ដែលអាចកើតឡើងចំពោះសុវត្ថិភាពតាមប្រព័ន្ធអនឡាញដែរ។ ទោះជាយ៉ាងនេះក្តី ការព្យាយាមតាមឱ្យទាន់រាល់ការផ្លាស់ប្តូរនៃការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់កុមារ អាចជួយការពារពួកគេឱ្យមានសុវត្ថិភាពពីហានិភ័យថ្មីៗដែលអាចនឹងកើតមានឡើង។

## ផ្តល់ការគាំទ្រនានា

កុមារត្រូវដឹងថាពួកគេអាចនិយាយប្រាប់ដោយបើកចំហពីបញ្ហារបស់ពួកគេបាន។ ទោះបីជាអ្នកឃើញថាកុមារបានចូលរួមក្នុងសកម្មភាពតាមប្រព័ន្ធអនឡាញ ដែលអាចធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យក៏ដោយ អ្នកមិនគួរស្តីបន្ទោសពួកគេទេ តែត្រូវបង្ហាញថាអ្នកនៅទីនោះដើម្បីជួយពួកគេ។ នៅពេលណាដែលកុមារមានអារម្មណ៍ជឿទុកចិត្ត ពួកគេនឹងមករកអ្នកដើម្បីទទួលបានការគាំទ្រ។

## សូមរក្សាឧបករណ៍ និងកម្មវិធីឱ្យមានសុវត្ថិភាព

ត្រូវប្រាកដថាឧបករណ៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាននៅផ្ទះរបស់អ្នក ត្រូវបានកំណត់នូវវិធានសុវត្ថិភាព ដែលវិធានទាំងនោះរួមមានការប្រើប្រាស់ពាក្យសម្ងាត់ដែលមិនងាយគេលួចប្រើប្រាស់បាន ការគ្រប់គ្រងការចូលប្រើគេហទំព័រ និងកម្មវិធីផ្សេងៗទៀតតាមប្រព័ន្ធអនឡាញ ដើម្បីធានាថាកុមារនឹងមិនឃើញនូវរូបភាព-សម្ភារៈដែលមិនសមរម្យ។

## លើកទឹកចិត្តឱ្យមានការអនុវត្តប្រកបដោយសុវត្ថិភាព

បង្រៀនកូនរបស់អ្នកឱ្យមានភាពឆ្លាតវៃនៅពេលអនឡាញ។ ភាពឆ្លាតវៃទាំងនោះរួមមាន ការមិនចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួន ការមិនជួបផ្ទាល់ជាមួយមនុស្សចម្លែកដែលកុមារស្គាល់តែតាមប្រព័ន្ធអនឡាញ ការមិនទទួលយកឯកសារ ឬរូបភាពពីមនុស្សដែលមិនស្គាល់ ការពិនិត្យមើលព័ត៌មានដើម្បីប្រាកដថាអាចជឿទុកចិត្តបាន ក៏ដូចជាការប្រាប់ដល់មនុស្សពេញវ័យ ប្រសិនបើមានអ្វីមិនល្អអាចកើតឡើង។

## សូមកំណត់ពេលវេលាប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ

(សូមប្រាប់ដល់កុមារពីហេតុផលដែលអាចទទួលយកបាន)

ប្រសិនបើអ្នកកត់សម្គាល់ថាកូនរបស់អ្នកចំណាយពេលច្រើនលើសលប់លើប្រព័ន្ធអ៊ីនធឺណិត ឬញៀននឹងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ឬហ្គេមកំសាន្តតាមអនឡាញ រឿងល្អបំផុតដែលអ្នកត្រូវធ្វើគឺនិយាយជាមួយពួកគេ ដើម្បីឱ្យពួកគេកាត់បន្ថយការប្រើប្រាស់អ៊ីនធឺណិត។ ធ្វើដូច្នេះ ពួកគេនឹងចេះវៃលែកពេលវេលាក្នុងការប្រើប្រាស់អ៊ីនធឺណិត។

## ការប្រាស្រ័យទាក់ទងគ្នាដោយបើកចំហ

ការនិយាយអំពីបញ្ហាផ្លូវភេទ ជាទូទៅហាក់មានភាពលាក់បាំង និងខ្មាស់អៀននៅឡើយ ហើយអ្នកប្រហែលជាមិនក្លាហានក្នុងការចាប់ផ្តើមការសន្ទនាលើប្រធានបទនេះនៅឡើយទេ។ អ្នកមិនត្រូវមានភាពខ្មាស់អៀនក្នុងការនិយាយអំពីបញ្ហាផ្លូវភេទនោះទេ ព្រោះវាមានសារៈសំខាន់ក្នុងការបង្ការគ្រោះថ្នាក់ដែលអាចកើតមាន។

ផលិតដោយ៖

APLE

ឧបត្ថម្ភការបោះពុម្ពដោយ៖

USAID
ជំនួយពីពលរដ្ឋអាមេរិក

unicef
ដើម្បីកុមារគ្រប់រូប